# ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ អសកម្ម

## អ្វីដែលលោកអ្នកត្រូវដឹង 2011-12

មានសេចក្តីថ្លែងព័ត៌មានថ្នាំបង្ការរោគ ជាភាសាអេស្ប៉ាញ៉ុល និងភាសាផ្សេងៗទៀតជាច្រើន ។ សូមមើលនៅ www.immunize.org/vis ។
Vaccine Information Statements are available in Spanish and many other languages. See www.immunize.org/vis

## 1 តើហេតុអ្វីបានជាត្រូវទទួលថ្នាំបង្ការរោគ?

**គ្រុនផ្តាសាយធំ “ហ្លូ” (flu) គឺជាជំងឺដែលឆ្លងរាលដាល ។**

គ្រុនផ្តាសាយធំបានបណ្តាលដោយសារ មេរោគវីរុសគ្រុនផ្តាសាយធំ ដែលអាចឆ្លងតាមរយៈការក្អក ការកណ្តាស់ ឬសំបោរ ។

អ្នកណាក៏អាចកើតគ្រុនផ្តាសាយធំនេះដែរ ប៉ុន្តែកំរិតធ្ងន់ធ្ងរខ្លាំងជាងគេ គឺក្នុងចំណោមកូនក្មេង ។ សំរាប់មនុស្សភាគច្រើន រោគសញ្ញាមានតែពីរបីថ្ងៃប៉ុណ្ណោះ ។ វារួមមាន :

- គ្រុនក្តៅ/ស្រៀវស្រាញ
- ឈឺបំពង់ក
- ឈឺសាច់ដុំ
- អស់កំឡាំង
- ក្អក
- ឈឺក្បាល
- ហៀរសំបោរ ឬតឹងច្រមុះ

រោគផ្សេងទៀតអាចមានសញ្ញារោគដូចគ្នា ហើយជាញឹកញាប់អាចច្រឡំថាជាគ្រុនផ្តាសាយធំ ។

កូនក្មេង មនុស្សអាយុ 65 ឆ្នាំ និងចាស់ជាង ស្ត្រីមានផ្ទៃពោះ និងមនុស្សដែលមានលក្ខណៈសុខភាពខ្លះដូចជារោគបេះដូង រោគសួត ឬរោគតម្រងនោម ឬខ្សោយប្រព័ន្ធស៊ាំរោគ អាចឈឺថ្កាត់ខ្លាំងជាង ។ គ្រុនផ្តាសាយធំ អាចបណ្តាលឲ្យមានគ្រុនក្តៅ និងហើមសួត ព្រមទាំងធ្វើឲ្យលក្ខណៈសុខភាពដែលមានស្រាប់ហើយកាន់តែធ្ងន់ធ្ងរឡើង ។ វាអាចបណ្តាលឲ្យរាករូស និងប្រកាច់ក្នុងកូន ក្មេងៗ ។ ជារៀងរាល់ឆ្នាំ មានមនុស្សរាប់ពាន់នាក់បានស្លាប់ដោយសារ គ្រុនផ្តាសាយធំ ហើយក៏មានកាន់តែច្រើននាក់ទៀត ត្រូវការសំរាន្តនៅមន្ទីរពេទ្យ ។

តាមរយៈការចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ អ្នកអាចការពារខ្លួនអ្នក អំពីគ្រុនផ្តាសាយធំ ទាំងអាចនឹងជៀសវាងការចំឡងគ្រុនផ្តាសាយធំ ទៅអ្នកផ្សេងៗទៀត ។

## 2 ថ្នាំបង្ការរោគគ្រុនផ្តាសាយធំអសកម្ម

ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ មានពីរប្រភេទ :

1. **ថ្នាំបង្ការរោគគ្រុនផ្តាសាយធំអសកម្ម** (ងាប់) ឬហៅថា "Flu Shot" (ថ្នាំចាក់ការពារគ្រុនផ្តាសាយធំ) ត្រូវបានចាក់ដោយម្ជុល ។

2. **ថ្នាំបង្ការរោគគ្រុនផ្តាសាយធំរស់ដែលខ្សោយ** (អន់ខ្សោយ) ត្រូវបានបាញ់ចូលតាមរន្ធច្រមុះ ។ *ថ្នាំបង្ការរោគនេះ គឺបានរៀបរាប់ក្នុងសេចក្តីថ្លែងព័ត៌មានថ្នាំបង្ការរោគ មួយដោយឡែកទៀត ។*

ថ្នាំបង្ការរោគគ្រុនផ្តាសាយធំអសកម្ម “កំរិត-ខ្ពស់” គឺមានសំរាប់មនុស្សអាយុ 65 ឆ្នាំ និងចាស់ជាង ។ សូមសួរគ្រូពេទ្យរបស់អ្នក សំរាប់ព័ត៌មានបន្ថែម ។

មេរោគវីរុសគ្រុនផ្តាសាយធំ តែងតែផ្លាស់ប្តូរ ដូច្នេះហើយការចាក់ថ្នាំបង្ការរោគប្រចាំឆ្នាំ ត្រូវបានគេឲ្យយោបល់ ។ ជារៀងរាល់ឆ្នាំ ពួកអ្នកវិទ្យាសាស្ត្រខំព្យាយាមផ្គូរផ្គងមេរោគវីរុសឲ្យត្រូវគ្នានឹងថ្នាំបង្ការរោគ សំរាប់អ្នកដែលងាយនឹងបណ្តាលឲ្យកើតគ្រុនផ្តាសាយធំ នៅឆ្នាំនោះ ។ ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ នឹងមិនការពារជំងឺបណ្តាលមកពីមេរោគ វីរុសផ្សេងៗទៀតទេ រួមទាំងមេរោគវីរុសដែលពុំមាននៅក្នុងថ្នាំចាក់ បង្ការរោគ ។

វាប្រើពេលដល់ទៅ 2 អាទិត្យ ក្រោយពីការចាក់ថ្នាំបង្ការរោគ ទំរាំចាប់ផ្តើមការពារបាន ។ ថ្នាំនេះអាចការពារគ្រុនផ្តាសាយធំបានដល់ទៅមួយឆ្នាំ ។

ថ្នាំបង្ការរោគគ្រុនផ្តាសាយធំអសកម្មមួយចំនួន មានសារធាតុម្យ៉ាងដែលត្រូវបានរក្សាទុក ហៅថា ធីមីរ៉ូសាល់ (thimerosal) ។ ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ ដែលគ្មានសារធាតុធីមីរ៉ូសាល់ ក៏មានដែរ ។ សូមសួរគ្រូពេទ្យរបស់អ្នក សំរាប់ព័ត៌មានបន្ថែម ។

## 3 តើអ្នកណា គួរតែចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំអសកម្ម?

**អ្នកណាខ្លះ**

មនុស្សទាំងអស់ដែលមាន**អាយុ 6 ខែ និងចាស់ជាង** គួរតែចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ ។

ការចាក់ថ្នាំបង្ការរោគ គឺជាសារៈសំខាន់សំរាប់មនុស្សដែលថិតក្នុងភាពគ្រោះថ្នាក់ខ្លាំង បណ្តាលមកពីគ្រុនផ្តាសាយធំ និងអ្នកនៅជិតស្និទ្ធនឹងគេ រួមទាំងបុគ្គលិកថែទាំសុខភាព និងនៅជិតស្និទ្ធនឹងក្មេងៗមានអាយុតិចជាង 6 ខែ ។

**ពេលវេលា**

ត្រូវចាក់ថ្នាំបង្ការរោគ យ៉ាងឆាប់រហ័សនៅពេលមានថ្នាំបង្ការរោគ ។ ធ្វើបែបនេះ វានឹងផ្តល់ការការពារបាន បើសិនរដូវគ្រុនផ្តាសាយធំឆាប់មកដល់ ។ អ្នកអាចចាក់ថ្នាំបង្ការរោគបាន ដរាបណាជំងឺនេះកំពុងតែកើតមាននៅក្នុងសហគមន៍របស់អ្នក ។

គ្រុនផ្តាសាយធំអាចកើតឡើងនៅពេលណាមួយ ប៉ុន្តែភាគច្រើនវាកើតឡើងចាប់តាំងពីខែតុលា រហូតដល់ខែឧសភា ។ នៅក្នុងរដូវថ្មីៗកន្លងមកនេះ ការកើតរោគភាគច្រើនបានកើតឡើងក្នុងខែមករា និងខែកុម្ភៈ ។ ការបានចាក់ថ្នាំបង្ការរោគ ក្នុងខែធ្នូ ឬសូម្បីតែក្រោយជាងនេះទៀត ក៏នៅតែនឹងផ្តល់ប្រយោជន៍ច្រើនក្នុងឆ្នាំនោះដែរ ។

មនុស្សចាស់ និងក្មេងជំទង់ៗភាគច្រើន ត្រូវការថ្នាំបង្ការរោគគ្រុនផ្តាសាយធំតែម្តងក្នុងមួយឆ្នាំ ។ ប៉ុន្តែក្មេងៗមានអាយុតិចជាង 9 ឆ្នាំ ត្រូវការចាក់ថ្នាំពីរដង ទើបអាចបានការពារ ។ សូមសួរគ្រូពេទ្យរបស់អ្នក ។

ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ អាចបានផ្តល់ឲ្យនៅពេលព្រមគ្នា ជាមួយនឹងថ្នាំបង្ការរោគផ្សេងទៀតដែរ រួមទាំងថ្នាំបង្ការរោគហើមសួតផង ។

## 4 មនុស្សមួយចំនួន មិនគួរគប្បីចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំអសកម្មទេ ឬគួរតែរង់ចាំ ។

- ប្រាប់គ្រូពេទ្យរបស់អ្នក បើអ្នកមានប្រតិកម្មខ្លាំងអ្វីមួយ (យាយីអាយុជីវិត) រួមទាំងប្រតិកម្មខ្លាំងនឹងពងសត្វ ។ ការប្រតិកម្មខ្លាំងនឹងគ្រឿងផ្សំអ្វីមួយនៃថ្នាំបង្ការរោគ អាចនឹងជាមូលហេតុមិនចាំបាច់ចាក់ថ្នាំបង្ការរោគ ។ ការមានប្រតិកម្មនឹងថ្នាំបង្ការរោគគ្រុនផ្តាសាយធំ គឺកម្រមានណាស់ ។
- ប្រាប់គ្រូពេទ្យរបស់អ្នក បើអ្នកធ្លាប់មានប្រតិកម្មខ្លាំង បន្ទាប់ពីចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ ។
- ប្រាប់គ្រូពេទ្យរបស់អ្នក បើអ្នកធ្លាប់មានរោគ Guillain-Barré Syndrome (ជារោគកំរើកពុំរួចដ៏ធ្ងន់ធ្ងរ ដែលហៅកាត់ថា GBS ដែរ) ។ គ្រូពេទ្យរបស់អ្នក នឹងជួយអ្នកសំរេចថាតើថ្នាំបង្ការរោគណាមួយដែលបានឲ្យយោបល់សំរាប់អ្នក ។

- មនុស្សដែលឈឺថ្កាត់មធ្យម ឬខ្លាំង តាមធម្មតាគួរតែរង់ចាំរហូតទាល់តែជាសះស្បើយ មុននឹងចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយធំ ។ បើអ្នកឈឺថ្កាត់ ត្រូវពិគ្រោះជាមួយគ្រូពេទ្យ ឬពេទ្យរបស់អ្នក ថាតើគួរតែណាត់ពេលចាក់ថ្នាំបង្ការរោគលើកក្រោយទៀត ឬជាយ៉ាងណា ។ មនុស្សដែលឈឺថ្កាត់ស្រាលៗ តាមធម្មតាអាចចាក់ថ្នាំបង្ការរោគនេះបាន ។

## 5 តើមានគ្រោះថ្នាក់អ្វីខ្លះ បណ្តាលពីថ្នាំបង្ការរោគគ្រុនផ្តាសាយធំអសកម្ម?

ថ្នាំបង្ការរោគ ក៏ដូចនឹងថ្នាំផ្សេងៗទៀតដែរ វាអាចបណ្តាលឲ្យមានបញ្ហាធ្ងន់ធ្ងរ ដូចជាមានប្រតិកម្មខ្លាំង ជាដើម ។ ភាពគ្រោះថ្នាក់នៃថ្នាំបង្ការរោគ ដែលបណ្តាលឲ្យគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬស្លាប់ គឺមានតិចតួចណាស់ ។

បញ្ហាធ្ងន់ធ្ងរបណ្តាលពីថ្នាំបង្ការរោគគ្រុនផ្តាសាយធំអសកម្ម គឺកម្រមានណាស់ ។ មេរោគវីរុស នៅក្នុងថ្នាំបង្ការរោគគ្រុនផ្តាសាយធំ ត្រូវបានសំឡាប់ ម៉្លោះហើយអ្នកមិនអាចកើតគ្រុនផ្តាសាយធំ ពីថ្នាំបង្ការរោគឡើយ ។

**បញ្ហាស្រាលៗ :**

- ឈឺសង្កៀរ ឡើងក្រហម ឬហើមនៅត្រង់កន្លែងមុខម្ជុល
- ស្អកសំឡេង ឈឺបំពង់ក ឬក្រហមភ្នែក ក្អក និងរមាស់
- គ្រុនក្តៅ
- ឈឺចាប់
- ឈឺក្បាល
- រមាស់
- អស់កំឡាំង

បើមានបញ្ហាទាំងនេះកើតឡើង តាមធម្មតាវាចាប់ផ្តើមភ្លាមបន្ទាប់ពីបានចាក់ថ្នាំ ហើយមានរយៈពេលពី 1-2 ថ្ងៃ ។

**បញ្ហាមធ្យម :**

កូនក្មេងដែលទទួលថ្នាំបង្ការរោគគ្រុនផ្តាសាយធំ និងថ្នាំបង្ការរោគរលាក ប្រព័ន្ធទងសួត (PCV13) នៅពេលព្រមគ្នា អាចបង្កើនឲ្យមាន ការប្រកាច់ដែលបណ្តាលមកពីគ្រុនក្តៅ ។ សូមសួរគ្រូពេទ្យរបស់អ្នក សំរាប់ព័ត៌មានបន្ថែម ។

ប្រាប់គ្រូពេទ្យរបស់អ្នក បើសិនក្មេងដែលទទួលថ្នាំបង្ការរោគគ្រុនផ្តាសាយធំ ធ្លាប់មានការប្រកាច់ ។

**បញ្ហាធ្ងន់ធ្ងរ :**

- ប្រតិកម្មដែលយាយីអាយុជីវិត បណ្តាលពីថ្នាំបង្ការរោគ គឺកម្រមានណាស់ ។ បើសិនជាវាកើតឡើង តាមធម្មតាវាមានក្នុងពេលពីរបីនាទី ទៅពីរបីម៉ោង បន្ទាប់ពីបានចាក់ថ្នាំ ។
- នៅក្នុងឆ្នាំ 1976 ថ្នាំបង្ការរោគគ្រុនផ្តាសាយធំមួយប្រភេទហៅថា គ្រុនផ្តាសាយជ្រូក (swine flu) ទាក់ទងនឹងរោគ Guillain-Barré Syndrome (GBS) ។ ចាប់តាំងពីគ្រានោះមក ថ្នាំបង្ការរោគគ្រុនផ្តាសាយធំពុំបានបង្ហាញច្បាស់លាស់ ថាទាក់ទងនឹងរោគ GBS ទេ ។ ក៏ប៉ុន្តែបើមានគ្រោះថ្នាក់នៃរោគ GBS បណ្តាលមកពីថ្នាំបង្ការរោគគ្រុនផ្តាសាយធំ ក្នុងពេលបច្ចុប្បន្ននេះ វានឹងពុំមានលើសពី 1 ឬ 2 ករណីក្នុងបណ្តាមនុស្សមួយលាននាក់ ដែលបានចាក់ថ្នាំបង្ការរោគឡើយ ។ នេះគឺតិចយ៉ាងអនេក បើប្រៀបទៅនឹងភាពគ្រោះថ្នាក់ ធ្ងន់ធ្ងរអំពីគ្រុនផ្តាសាយធំ ដែលអាចការពារបានដោយការចាក់ថ្នាំបង្ការរោគ ។

> ថ្នាំបង្ការរោគគ្រុនផ្តាសាយធំអសកម្ម មានឈ្មោះល្បីមួយប្រភេទហៅថា Afluria **មិនគួរបានផ្តល់ទៅឲ្យ**ក្មេងៗអាយុ 8 ឆ្នាំ ឬក្មេងជាង លើកលែងតែក្នុងកាលៈទេសៈពិសេស ។ បញ្ហាជាប់ទាក់ទងនឹងថ្នាំបង្ការរោគ អាចមានគ្រុនក្តៅ និងមានប្រកាច់ ជាប់ទាក់ទងនឹងគ្រុនក្តៅ ក្នុងក្មេងតូចៗ នៅក្នុងប្រទេសអូស្ត្រាលី ។ គ្រូពេទ្យរបស់អ្នក អាចផ្តល់ព័ត៌មានឲ្យអ្នកថែមទៀត ។

សុវត្ថិភាពនៃថ្នាំបង្ការរោគ គឺតែងតែត្រូវបានឃ្លាំមើលជានិច្ច ។ សំរាប់ព័ត៌មានបន្ថែម សូមមើល : **www.cdc.gov/vaccinesafety/Vaccine_Monitoring/Index.html**
និង
**www.cdc.gov/vaccinesafety/Activities/Activities_Index.html**

## 6 ចុះបើសិនជាមានប្រតិកម្មធ្ងន់ធ្ងរវិញនោះ?

### តើខ្ញុំគួរតែឃ្លាំរកមើលអ្វី?

លក្ខណៈចំឡែកអ្វីមួយខុសពីធម្មតា ដូចជាគ្រុនក្តៅខ្លាំង ឬអាកប្បកិរិយាប្រែប្រួល ។ សញ្ញានៃប្រតិកម្មធ្ងន់ធ្ងរ អាចរួមមាន ការពិបាកដកដង្ហើម ស្អកសំឡេង ឬការតឹងដង្ហើម មានកន្ទួលលើស្បែក ស្លេកស្លាំង ខ្សោយកំឡាំង ចង្វាក់បេះដូងដើរញាប់ៗ ឬវិលមុខ ។

### តើខ្ញុំត្រូវធ្វើយ៉ាងណា?

- **ទូរស័ព្ទ**ទៅគ្រូពេទ្យ ឬយកមនុស្សនោះទៅជួបគ្រូពេទ្យជាបន្ទាន់ ។
- **ប្រាប់**គ្រូពេទ្យ អំពីអ្វីដែលបានកើតឡើង បានកើតឡើងនៅថ្ងៃខែឆ្នាំណា និងវេលាម៉ោងប៉ុន្មាន ហើយបានទទួលថ្នាំបង្ការរោគពីពេលណា ។
- **ស្នើ**គ្រូពេទ្យរបស់អ្នក ឲ្យរាយការណ៍អំពីប្រតិកម្ម ដោយបំពេញក្រដាសប្រព័ន្ធរបាយការណ៍ព្រឹត្តិការណ៍ប្រតិកម្មថ្នាំបង្ការរោគ (Vaccine Adverse Event Reporting System, VAERS) ។ ឬអ្នកអាចបំពេញសេចក្តីរាយការណ៍នេះ តាមរយៈវ៉ិបសៃត៍របស់ VAERS នៅឯ **www.vaers.hhs.gov** ឬដោយទូរស័ព្ទទៅលេខ **1-800-822-7967** ។

*VAERS មិនផ្តល់ឱវាទផ្នែកសុខភាពឡើយ ។*

## 7 កម្មវិធីជាតិ ធានារ៉ាប់រងគ្រោះថ្នាក់បណ្តាលពីថ្នាំបង្ការរោគ

កម្មវិធីជាតិ សំណងគ្រោះថ្នាក់បណ្តាលមកពីថ្នាំបង្ការរោគ (National Vaccine Injury Compensation Program, VICP) បានបង្កើតឡើងនៅឆ្នាំ 1986 ។

បុគ្គលណាដែលជឿថាគេប្រហែលជាមានគ្រោះថ្នាក់ ដោយសារថ្នាំបង្ការរោគ អាចស្វែងយល់ថែមទៀតអំពីកម្មវិធី និងអំពីការប្តឹងសំណង ដោយទូរស័ព្ទទៅលេខ **1-800-338-2382** ឬមើលវ៉ិបសៃត៍របស់ VICP នៅឯ **www.hrsa.gov/vaccinecompensation** ។

## 8 តើខ្ញុំធ្វើយ៉ាងណា ឲ្យបានយល់ដឹងបន្ថែមទៀត?

- សាកសួរគ្រូពេទ្យរបស់អ្នក ។ គេអាចផ្តល់ពត៌មានដែលមានភ្ជាប់ជាមួយប្រអប់ថ្នាំ ឬផ្តល់យោបល់ពីព័ត៌មានប្រភពផ្សេងៗទៀត ។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលប្រចាំតំបន់ ឬក្រសួងសុខាភិបាលរដ្ឋ ។
- សូមទាក់ទងទៅមណ្ឌលទប់ស្កាត់ និងបង្ការរោគ (Centers for Disease Control and Prevention, CDC) :
  - សូមទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - សូមមើលវ៉ិបសៃត៍របស់ CDC នៅ **www.cdc.gov/flu**

DEPARTMENT OF HEALTH AND HUMAN SERVICES
CENTERS FOR DISEASE CONTROL AND PREVENTION

Vaccine Information Statement (Interim) 42 U.S.C. §300aa-26
Inactivated Influenza Vaccine IMM-569CAM – Cambodian (7/26/11)
Translated by Transcend Translations, Davis, CA www.transcend.net